# ឆ្លើយតបទៅនឹងអត្ថបទ:
## ភ្នាក់ងារផ្តាច់ព្រលឹង (ទស្សនាវដ្តីស្វែងរកការពិតលេខ ៣១)

“ប្រជាជនកម្ពុជាត្រូវបានសម្លាប់ចោលដោយគ្មានមូលហេតុ ឬដោយសារមិនសូវខិតខំធ្វើការ ឬដោយសារខ្លួនចេះដឹងជ្រៅជ្រះ ឬជាជនជាតិ ។ ខ្មែរក្រហមទទួលមេរៀនយ៉ាងចំណាប់ចំណូនពីពួកណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទីពីរ” ។

សេចក្តីដកស្រង់ខាងលើមកពី ឌិត ប្រ៉ាន នៅមហាវិទ្យាល័យអាមេរិកាំង នោះគឺជាសេចក្តីលម្អៀងទូទៅមួយ និងជាការយល់ខុសទៅលើប្រវត្តិសាស្ត្រមហាពិឃាត ។ នៅក្នុងខ្ទឹមសារនេះ ឌិត ប្រ៉ាន និយាយដូច អាឡិច ហ៊ីនតុន ដែរថា មេរៀននៃមហាពិឃាតគឺបានមកពីពួកណាហ្ស៊ី ។ ប៉ុន្តែសេចក្តីដកស្រង់ខាងក្រោមបានមកពីអតីតក្រុមកុម្មុយនិស្តនិងអ្នកគាំទ្រកុម្មុយនិស្តដែលនិយាយផ្សេងពីនេះ ។ តើណាហ្ស៊ីជាអ្នករៀនពីជនកុម្មុយនិស្ត ឬជនកុម្មុយនិស្តរៀនពីពួកណាហ្ស៊ី? នេះគឺជាសេចក្តីដកស្រង់ចេញពីស្នាដៃនិពន្ធរបស់លោក ស្ទីវហ្វាន គូទ័រ (និពន្ធនាយក) ដែលមានចំណងជើងថា “សៀវភៅខ្មៅកុម្មុយនិស្តៈ ឧក្រិដ្ឋកម្ម ភេរវកម្ម ការបង្ក្រាបមិនឲ្យងើបមុខរួច” បោះពុម្ពនៅរោងពុម្ពសាកលវិទ្យាល័យ ហាវើដ ទីក្រុងខែមប្រ៊ីច ឆ្នាំ១៩៩៧ ទំព័រទី១៥ ។

វិធីសាស្ត្រអនុវត្តដោយ ឡេនីន រួចយកទៅធ្វើឲ្យសុក្រឹតដោយ ស្តាលីន ព្រមទាំងកូនចៅ ធ្វើឲ្យនឹកឃើញដល់វិធីសាស្ត្រប្រើប្រាស់ដោយពួកណាហ្ស៊ី ប៉ុន្តែជាញឹកញយ នេះគឺដោយសារពួកណាហ្ស៊ីប្រើប្រាស់បច្ចេកទេសរបស់ ឡេនីន ។ រូដុល ហេស ដែលទទួលបន្ទុករៀបចំចាត់ចែងជំរំអូស្វ៊ីត ហើយក្រោយមកតែងតាំងជាមេបញ្ជាការនៅជំរំនេះតែម្តង គឺជាឧទាហរណ៍ឥតខ្ចោះមួយបញ្ជាក់ពីបញ្ហានេះ ។ “ការិយាល័យសន្តិសុខកណ្តាលនៅរិច បានចេញបញ្ជាទៅមេបញ្ជាការនានាឲ្យប្រមូលរបាយការណ៍ដែលពាក់ព័ន្ធទៅនឹងជំរំប្រមូលផ្តុំរុស្ស៊ី ។ ប្រការទាំងនេះ រៀបរាប់ជាលម្អិតអំពីស្ថានភាពនៅក្នុងជំរំនិងការរៀបចំជំរំ ដូចដែលបានផ្តល់ដោយអតីតអ្នកទោសដែលមានវាសនាបានរួចផុតពីគុក ។ ការផ្តោតសំខាន់គឺទៅលើចំណុចដែលថាជនជាតិរុស្ស៊ីបានកម្ទេចប្រជាជាតិទាំងមូល តាមរយៈការបង្ខំឲ្យធ្វើការធ្ងន់ៗ” ។ ប៉ុន្តែការពិតដែលថាបច្ចេកទេសនៃអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំនិង (ប្រពលភាពអាំងតង់ស៊ីតេ) ដែលមានដើមកំណើតឡើងស្របជាមួយនឹងជនកុម្មុយនិស្ត ហើយបានជាពួកណាហ្ស៊ីត្រូវបានជំរុញដោយជនកុម្មុយនិស្ត បើតាមគំនិតយើងគឺមិនមានន័យថាមនុស្សម្នាក់អាចសន្និដ្ឋានថាជាការពិតបញ្ជាក់ពីទំនាក់ទំនងហេតុនិងបច្ច័យ (រវាងបដិវត្តន៍បុលសេវិក និង ការកើតឡើងនៃណាហ្ស៊ីនិយម ទេ) ។

ខ្ញុំមិនអាចជឿសាសនារ៉ូម៉ាំងកាតូលិក ជាងគណៈនិកាយរ៉ូម៉ាំងកាតូលិកនៃសាសនាគ្រិស្តបានទេ ។ សូមគិតថានេះជាអត្ថបទមួយដែល ឆាំង យុ បានស្នើឲ្យខ្ញុំសរសេរ (រិះគន់) ទៅលើអត្ថបទរបស់ អាឡិច ហ៊ីនតុន ដែលមានចំណងជើងថា “ភ្នាក់ងារផ្តាច់ព្រលឹង” ។ សូមទទួលការគោរពដ៏កក់ក្តៅអំពីខ្ញុំ ។

**ឌិត ណាវ៉ាន់ គីរី**
**សាកលវិទ្យាល័យ ចន ហប់គីន**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **អប់រំមនុស្ស:** គឺការអប់រំកសាងសង្គមនិយម ។

◆ **ហិរញ្ញវត្ថុ:** គឺខ្លួនឧបត្ថម្ភខ្លួនឯករាជ្យម្ចាស់ការហិរញ្ញវត្ថុបានមកពីកសិកម្មហើយត្រូវសន្សំសំចៃជាអតិបរមា ។

(កំណត់ហេតុលេខ ២០៩)

◆ **កម្មាជីវរូបនីយកម្ម:** គឺរស់នៅក្នុងការងារ ។

◆ **អត្តនោម័តិ:** អនុម័តខ្លួនឯង ។

◆ **ឥទ្ធិពល:** កម្លាំងដ៏ខ្លាំងក្លាឬមោះមុត ។

(កំណត់ហេតុ TSL N-97, N-11 លេខ ១០)